# សុន្ទរកថារបស់**ឯកឧត្តម គូម៉ាម៉ារ៉ូ យូជិ**
## ឯកអគ្គរាជទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា
## ថ្លែងក្នុងពិធីចុះហត្ថលេខាលើកិច្ចសន្យាផ្តល់ជំនួយសម្រាប់
## គម្រោងទ្រង់ទ្រាយតូចសន្តិសុខមនុស្សជាតិរបស់ប្រទេសជប៉ុន
២១ មិនា ២០១៣

**សូមគោរព លោកស្រី ចាន់ ធារី នាយិកាប្រតិបត្តិ សម្ព័ន្ធសុខភាពកុមារ និងសុខភាពបន្តពូជ!**

**សូមគោរព លោក កែវ ផន នាយកប្រតិបត្តិ មជ្ឈមណ្ឌលដើម្បីអភិវឌ្ឍន៍!**

**សូមគោរព លោក ព្រុំ ណឹម ប្រធានក្រុមប្រឹក្សាឃុំចោងម៉ោង ស្រុកទឹកផុស ខេត្តកំពង់ឆ្នាំង!**

**សូមគោរព អស់លោក លោកស្រី!**

ខ្ញុំមានសេចក្តីសោមនស្សរីករាយដើម្បីចូលរួមក្នុងពិធីចុះហត្ថលេខាលើកិច្ចសន្យាផ្តល់ជំនួយចំនួន៣ក្នុងថ្ងៃនេះសម្រាប់គម្រោងទ្រង់ទ្រាយតូចសន្តិសុខមនុស្សជាតិ។ ខ្ញុំក៏មានសេចក្តីសោមនស្សរីករាយយ៉ាងខ្លាំងផងដែរដែលកិច្ចសន្យាផ្តល់ជំនួយទាំងនេះត្រូវបានធ្វើឡើងក្នុងឆ្នាំ២០១៣ដែលជាឆ្នាំខួបអនុស្សាវរីយ៍ទី៦០នៃទំនាក់ទំនងមិត្តភាពជប៉ុន-កម្ពុជា។

គម្រោងទាំង៣ដែលយើងបានចុះហត្ថលេខានៅថ្ងៃនេះមានគោលដៅកែលម្អគុណភាពទឹកស្អាតសម្រាប់ទទួលទាន និងបរិស្ថានអប់រំសម្រាប់កុមារនៅតំបន់ជនបទ។ វិស័យអប់រំនិងការផ្គត់ផ្គង់ទឹកស្អាតមានសារៈសំខាន់សម្រាប់ការអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គមកិច្ចនៅកម្ពុជាដែលរាជរដ្ឋាភិបាលកម្ពុជាបានផ្តល់អាទិភាពខ្ពស់ទៅលើវិស័យទាំងនេះសម្រាប់យុទ្ធសាស្ត្រអភិវឌ្ឍន៍របស់ខ្លួន។

ប្រទេសជប៉ុនបាននិងកំពុងបន្តជួយដល់កិច្ចខិតខំប្រឹងប្រែងអភិវឌ្ឍន៍របស់រាជរដ្ឋាភិបាលកម្ពុជាចាប់តាំងពីឆ្នាំ១៩៩២មកដោយសម្របតាមគោលនយោបាយនៃជំនួយឧបត្ថម្ភរបស់ខ្លួនឲ្យស្របទៅតាមគោលនយោបាយអភិវឌ្ឍន៍របស់កម្ពុជា។ គម្រោងទាំងនេះអនុឡោមទៅតាមគោលនយោបាយនៃជំនួយឧបត្ថម្ភរបស់ជប៉ុនចំពោះកម្ពុជា និងត្រូវទៅតាមគោលការណ៍នៃគម្រោងជំនួយខ្នាតតូចដើម្បីលើកស្ទួយសន្តិសុខមនុស្សជាតិសម្រាប់ប្រជាជនងាយរងគ្រោះផងដែរ។

ជំនួយទី១មានថវិកាសរុប១០០,៧៤៥ដុល្លាអាមេរិកផ្តល់ជូនសម្ព័ន្ធសុខភាពកុមារនិងសុខភាពបន្តពូជសម្រាប់ការតំឡើងប្រព័ន្ធចម្រោះទឹកក្នុងស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ។ តាមរយៈការតំឡើងប្រព័ន្ធនេះ ការទទួលបានទឹកស្អាតរបស់ប្រជាជនជាង១១,០០០នាក់ដែលកំពុងប្រឈមនឹងបញ្ហាសុខភាពដោយការប្រើប្រាស់ទឹកមិនស្អាតនឹងមានភាពប្រសើរឡើង។

ជំនួយទី២មានថវិកាសរុប ៤០,៦៦៦ដុល្លាអាមេរិក ផ្តល់ជូនមជ្ឈមណ្ឌលដើម្បីអភិវឌ្ឍន៍សម្រាប់សាងសង់អគារផ្ទះកុមារដែលមានពីរបន្ទប់និងបរិក្ខារអនាម័យ ព្រមទាំងបំពាក់សង្ហារឹមដែលចាំបាច់ក្នុងឃុំទឹកល្អក់ ស្រុកគងពិសី ខេត្តកំពង់ស្ពឺ។ យើងសង្ឃឹមថាគម្រោងនេះនឹងផ្តល់បរិស្ថានស្អាត និង អនាម័យដល់កុមារតូចៗ ប្រមាណ ១៤០ នាក់ដែលបច្ចុប្បន្នកំពុងប្រើប្រាស់មណ្ឌលសហគមន៍ជាផ្ទះកុមារ។

ជំនួយទី៣មានថវិកាសរុប៨១,១០០ដុល្លាអាមេរិកផ្តល់ជូនក្រុមប្រឹក្សាឃុំចោងម៉ោងស្រុកទឹកផុស ខេត្តកំពង់ឆ្នាំងសម្រាប់ការសាងសង់អគារសិក្សាមួយខ្នងមាន៥បន្ទប់ និងបរិក្ខារអនាម័យ ព្រមទាំងបំពាក់គ្រឿងសង្ហារឹមដែលចាំបាច់នៅសាលាបឋមសិក្សាចោងម៉ោង។ យើងរំពឹងថាគម្រោងនេះនឹងជួយកែលម្អបរិស្ថានសិក្សារបស់សិស្សានុសិស្សជាង២៥០នាក់ក្នុងសាលាបឋមសិក្សាចោងម៉ោង។

ខ្ញុំសង្ឃឹមថាគម្រោងដែលចុះហត្ថលេខានៅថ្ងៃនេះនឹងត្រូវបានអនុវត្តយ៉ាងរលូន និងថែទាំយ៉ាងត្រឹមត្រូវដើម្បីឲ្យប្រជាជនកាន់តែច្រើនអាចទទួលបានអត្ថប្រយោជន៍ពីគម្រោងទាំងនេះ។

ចុងក្រោយនេះ ខ្ញុំក៏សង្ឃឹមផងដែរថាកិច្ចសហប្រតិបត្តិការនេះនឹងជួយពង្រឹងជាបន្តទៅទៀតនូវទំនាក់ទំនងមិត្តភាពរវាងប្រជាជនជប៉ុន និងប្រជាជនកម្ពុជា។

សូមអរគុណចំពោះការយកចិត្តទុកដាក់ស្តាប់!